# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

# ការពង្រឹងផលិតកម្មនិងប្រាក់ចំណេញនៃវិស័យកសិកម្ម ក្នុងតំបន់ទន្លេមេគង្គ

ការលើកកម្ពស់ដល់ការអនុវត្តក្នុងវិស័យកសិកម្មនៅក្នុងតំបន់ទន្លេមេគង្គ និងបទពិសោធន៍សំរាប់គោលនយោបាយ នឹងត្រូវបានពិភាក្សានៅឯអង្គសិក្ខាសាលាមួយនារាជធានីភ្នំពេញក្នុងសប្តាហ៍នេះ។

នាថ្ងៃនេះ លោកជំទាវ **អាលីសុន បើរវ៉ូ** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានបើកសិក្ខាសាលាស្តីពី «កិច្ចសន្ទនាគោលនយោបាយអំពីអនាគតដំណាំស្រូវ ៖ ការស្រាវជ្រាវអំពីប្រព័ន្ធផលិតកម្មកសិកម្មដែលផ្អែកលើដំណាំស្រូវនៅតំបន់ទន្លេមេគង្គ។»

លោកជំទាវឯកអគ្គរាជទូត បើរវ៉ូ បានមានប្រសាសន៍ថា «សិក្ខាសាលានេះ ត្រូវបានធ្វើឡើងបន្ទាប់ពីមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់កម្មវិធីស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) បានវិនិយោគអស់ទឹកប្រាក់សរុប១៥,៨លានដុល្លាអូស្ត្រាលី ចាប់ពីឆ្នាំ២០០៩មក លើគម្រោងមួយចំនួននៃផលិតភាពកសិកម្មនិងការសិក្សាស្រាវជ្រាវសំរាប់គោលនយោបាយ។»

«ជារួម គម្រោងទាំងនេះបាននាំមកនូវការគ្រប់គ្រងដែលល្អជាងគេ បច្ចេកវិទ្យាទំនើប ការដាំដុះសមស្រប ការធ្វើម៉ាខិតធីងទីផ្សារនិងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មប្រកបដោយគោលដៅ ព្រមទាំងការសិក្សាស្រាវជ្រាវដើម្បីគោលនយោបាយ។»

មានអ្នកពាក់ព័ន្ធក្នុងកម្មវិធីនេះប្រមាណ៦០នាក់ដែលមកពីប្រទេសកម្ពុជា ឡាវ វៀតណាម និងអូស្ត្រាលី បានចូលរួមក្នុងអង្គសិក្ខាសាលានេះ ដែលបានប្រារព្ធនៅសណ្ឋាគារកាំបូឌីយ៉ាណា នារាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៧ ដល់ទី៩ ខែឧសភា ឆ្នាំ២០១៤។

លោកបណ្ឌិត **អ៊ុក មករា** ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ដែលជាដៃគូស្រាវជ្រាវសំខាន់របស់កម្មវិធី បានមានប្រសាសន៍ថា កម្មវិធី

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ស្រាវជ្រាវប្រព័ន្ធផលិតកម្មកសិកម្មដែលផ្អែកលើដំណាំស្រូវ បានកំពុងជួយដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងដល់ជីវភាពរស់នៅរបស់ប្រជាជនជនបទ។

«ការសហការរវាងអ្នកវិទ្យាសាស្ត្រអូស្ត្រាលីនិងអន្តរជាតិ កំពុងតែជួយដល់ប្រជាជនកម្ពុជា ក្នុងការលើកកម្ពស់ជំនាញស្រាវជ្រាវរបស់យើង និងអភិវឌ្ឍយុទ្ធសាស្ត្រក្នុងការយកឈ្នះលើបញ្ហាប្រឈមចំបងនានា។»

អ្នកសម្របសម្រួលកម្មវិធី លោកស្រីបណ្ឌិត **ខារ៉ូលីន ឡឺមែរល៍** (Dr Caroline Lemerle) បានមានប្រសាសន៍ថា មជ្ឈមណ្ឌលACIAR បានផ្តោតទៅលើខ្លឹមសារសំខាន់សំរាប់គោលនយោបាយ ដែលអាចបកស្រាយចេញអំពីការស្រាវជ្រាវប្រព័ន្ធផលិតកម្មកសិកម្មដែលផ្អែកលើដំណាំស្រូវ។

«សិក្ខាសាលានេះមានគោលបំណងពង្រឹងនូវទំនាក់ទំនង និងការពិភាក្សារវាងអ្នកស្រាវជ្រាវ អ្នកធ្វើគោលនយោបាយដ៏មានឥទ្ធិពលក្នុងតំបន់ និងអ្នកមានឥទ្ធិពលដទៃទៀត។ វគ្គចាប់ផ្តើមនឹងផ្តោតជាទូទៅលើអនាគតរបស់ដំណាំស្រូវក្នុងតំបន់ទន្លេមេគង្គ មុននឹងចាប់ផ្តើមពិនិត្យលើខ្លឹមសារនានានៃកម្មវិធីស្រាវជ្រាវ។» កម្មវិធីស្រាវជ្រាវប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវ គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីបួនដែលបង្កើតដោយ មជ្ឈមណ្ឌលACIAR ក្រោមកម្មវិធីគំនិតផ្តួចផ្តើមនៃសន្តិសុខស្បៀងតាមរយៈការអភិវឌ្ឍន៍ជនបទ របស់រដ្ឋាភិបាលអូស្ត្រាលី។ ការស្រាវជ្រាវនេះ បានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ឡាវ និងបង់ក្លាដេស។

**ទំនាក់ទំនងពត៌មានៈ លោក សាយម៉ុន ហ៊ៀលឡូវស៍ អនុប្រធានបេសកកម្ម**

**ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០**

**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៤**